# បទឧក្រិដ្ឋកម្មសង្គ្រាម (War Crime)

និយាយជាសាមញ្ញ បទឧក្រិដ្ឋនេះ គឺជាការបំពានច្បាប់មនុស្សធម៌អន្តរជាតិ (international humanitarian law) ដូចជាការបំផ្លាញទ្រព្យសម្បត្តិ ឬសម្លាប់ជនត្រូវបានការពារ (protected persons)។ ក៏ប៉ុន្តែ ផ្អែកតាមការវិវត្តិនៃច្បាប់សង្គ្រាម សញ្ញាណនៃបទឧក្រិដ្ឋកម្មសង្គ្រាម ក៏មានការប្រែប្រួលផងដែរ។ បទឧក្រិដ្ឋនេះ ត្រូវបានចាត់ទៅតាមប្រភេទនៃការបំពាន ឬប្រភេទនៃជម្លោះ ដែលអាចជាជម្លោះក្នុងស្រុក (non-international arms conflict) ឬសង្គ្រាមអន្តរជាតិ (international armed conflicts)។

បទឧក្រិដ្ឋកម្មសង្គ្រាម អាចជាការបំពានច្បាប់ហ្សឺណែវ (law of Geneva) ឬ ច្បាប់ឡាអេ (law of the Hague)។ បទឧក្រិដ្ឋក្នុងសង្គ្រាមអន្តរជាតិ មានបទល្មើសដូចជា ៖ ការសម្លាប់ជនត្រូវបានការពារ (ប្រឆាំងនឹងមនុស្ស) ការប្រព្រឹត្តទារុណកម្ម ឬអំពើអមនុស្សធម៌ ដែលចូលក្នុងប្រភេទ ការបំពានធ្ងន់ធ្ងរ (grave breaches) និងប្រភេទប្រឆាំងនឹងទ្រព្យសម្បត្តិ ព្រមទាំងសិទ្ធិ ដូចជា ការបំផ្លាញធ្ងន់ធ្ងរ និងរឹបអូសទ្រព្យសម្បត្តិជាដើម។ ប្រភេទចុងក្រោយ បង្កមកពីវិធីសាស្ត្រនៃកាធ្វើសង្គ្រាម ដូចជា ការវាយប្រហារលើគោលដៅមិនមែនយោធា។

បន្ថែមពីលើវិធីសាស្ត្រនៃការធ្វើសង្គ្រាម ដែលការបំពាននាំឲ្យមានការទទួលខុសត្រូវ វាក៏មានការហាមឃាត់នូវមធ្យោបាយធ្វើសង្គ្រាម (prohibited means of warfare) ដូចជា ការប្រើប្រាស់អាវុធគីមី និងចុងក្រោយ ទង្វើបំពានលើជំនួយមនុស្សធម៌។ មាត្រា ៨(២)(ខ)(iii) នៃលក្ខន្តិកៈ ស្តីពី ICC ចែងជាបទល្មើស នូវសកម្មភាពវាយប្រហារលើសំភារៈបុគ្គលិកមនុស្សធម៌ និងប្រតិបត្តិការការពារសន្តិភាព។ នេះបើអនុលោមតាមអនុសញ្ញាស្តីពី សុវត្ថិភាពនៃបុគ្គលិកជំនួយ និង អង្គការសហប្រជាជាតិឆ្នាំ ១៩៩៤ (Convention on the Safety of United Nations and Associated Personnel)។

ការបំពានធ្ងន់ធ្ងរលើអនុសញ្ញាហ្សឺណែវ (ឧក្រិដ្ឋកម្មសង្គ្រាម) ស្ថិតចូលក្នុងយុត្តាធិការសកល (universal jurisdiction)។ សម្រាប់បទល្មើសទាំងអស់ គេត្រូវបង្ហាញពីចំណងទាក់ទងរវាងអំពើ និងសង្គ្រាម (nexus) និងធាតុផ្សំអត្តនោម័ត ដែលអាចជាការធ្វេសប្រហែស (negligence) ឬចេតនាផ្ទាល់សម្រាប់បទល្មើសខ្លះ (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp.566-568)។

**ខ្លឹមសារបន្ថែម៖** បទឧក្រិដ្ឋកម្មនេះ ត្រូវបានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ នៃកម្ពុជា (article 193 ) និង ស្ថិតក្នុងសម្ថកិច្ចបទល្មើស នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក) (Law on ECCC, Article 6)។